មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**ទេចរណកថារបស់ ម.ស.ម.ក**

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៣

# ម.ស.ម.ក សាទរចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សម្រាប់ចំណាត់ការរបស់លោកប្រឆាំងនឹងសំណុំរឿងលោក ឈូក បណ្ឌិត

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ស្វាគមន៍ចំពោះសេចក្ដីសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវបានរាយការណ៍ដោយកាសែត *ឌឺ ខេមបូឌា ដេលី* កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ (សាលាឧទ្ធរណ៍ចាត់ការលើសំណុំរឿងលោក ឈូក បណ្ឌិត ទំព័រទី១) ដើម្បីប្ដឹងជំទាស់ប្រឆាំងនឹងសេចក្ដីសម្រេចដ៏ចម្រូងចម្រាសរបស់សាលាដំបូងខេត្តស្វាយរៀង ចំពោះការទម្លាក់ចោលនូវការចោទប្រកាន់ទាំងអស់លើរូបលោក ឈូក បណ្ឌិត អតីតអភិបាលក្រុងបាវិត កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២។ លោក ឈូក បណ្ឌិត គឺជាជនសង្ស័យសំខាន់ម្នាក់ក្នុងការបាញ់ប្រហារលើកម្មការិនីរោងចក្រកាត់ដេរបីរូប ដែលបណ្ដាលឲ្យរងរបួសធ្ងន់ធ្ងរ ខណៈដែលពួកគេបានកំពុងតែធ្វើការតវ៉ានៅខាងក្រៅរោងចក្រមួយដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន កៅវ៉េ ស្លត លីមីតធីដ ក្នុងក្រុងបាវិត កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។ នៅក្នុងសេចក្ដីថ្លែងការណ៍ចុះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ('ម.ស.ម.ក អំពាវនាវឲ្យ ភូម៉ា (Puma) ដកខ្លួនចេញពីស្រុករបស់លោក បណ្ឌិត') ម.ស.ម.ក បានរិះគន់យ៉ាងខ្លាំងចំពោះសេចក្ដីសម្រេចទម្លាក់ចោលការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងលោក ឈូក បណ្ឌិត និងបានអំពាវនាវឲ្យ ភូម៉ា (Puma) ដែលជាអ្នកទិញដ៏សំខាន់របស់រោងចក្រនេះ ដកខ្លួនចេញពីប្រទេសកម្ពុជាជាការតវ៉ាប្រឆាំងនឹងនិទណ្ឌភាព។

អគ្គព្រះរាជអាជ្ញា លោក អ៊ុក សាវុធ បានមានប្រសាសន៍ថា គាត់បាន "*កំពុងតែចាត់ការលើសំណុំរឿងលោក ឈូក បណ្ឌិត ដើម្បីផ្ដន្ទាទោសនៅសាលាឧទ្ធរណ៍ ក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងបីនាក់*"។ ចំណាត់ការនេះត្រូវបានគេសង្ឃឹមថា សាលាឧទ្ធរណ៍នឹងពិនិត្យមើលដោយដាក់ស្ដែង និងមិនលម្អៀងទៅតាមភស្តុតាងដែលស្វែងរកបាន ចាត់តាំងសាក្សីឃើញផ្ទាល់ភ្នែកទាំងឡាយដោយការជឿជាក់ស្មើភាពគ្នា មិនចាប់អារម្មណ៍ពីសម្ពាធនយោបាយ ឬក៏ការជ្រៀតជ្រែកណាមួយឡើយ និងគោរពតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ភាគីដែលពាក់ព័ន្ធទាំងអស់។ ថ្វីត្បិតតែខណៈនេះគឺចាំបាច់ដែលលោក ឈូក បណ្ឌិត គឺជាជនគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញក្ដី មានភស្តុតាងគួរឲ្យជឿជាក់ដើម្បីបញ្ជាក់ថាថាលោក បណ្ឌិតអាចមានពិរុទ្ធភាព ដែលសវនាការពេញលេញ និងត្រឹមត្រូវគឺពិតជាត្រូវបានធានាថានឹងធ្វើឡើង។ ជា

ការផ្ដុយទាំងស្រុងទៅនឹងចំណាត់ការក្នុងទិសដៅដ៏ត្រឹមត្រូវ  កាសែត *ឌឹ ខេមបូឌា ដេលី* រាយការណ៍នៅពីថ្ងៃនេះ ទី០២ ខែមករា ឆ្នាំ២០១៣ ថា  នៅគ្រាដែលមានការជម្រុញពីក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃនឹងសរសេរនូវរបាយការណ៍មួយអំពីការពាក់ព័ន្ធនៃជនសង្ស័យដទៃ  ឈ្មោះ  ស  ចន្ថា  (‘ក្រសួងមហាផ្ទៃបានស្នើឲ្យធ្វើការស៊ើបអង្កេតបន្ថែមលើករណីបាញ់ប្រហារនៅតំបន់សេដ្ឋកិច្ចពិសេស  ទំព័រ១៨’) ដែលត្រូវបានចោទប្រកាន់កាលពីខែសីហា  ឆ្នាំ ២០១២ ពីបទបង្ករបួសស្នាមដោយអចេតនានៅក្នុងអំឡុងពេលនៃការបាញ់ប្រហារ តែលោក ស ចន្ថា បដិសេធការពាក់ព័ន្ធលើឧបទ្ទវហេតុនោះ។

**លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក មានប្រសាសន៍ថា៖**

*"អគ្គព្រះរាជអាជ្ញាគឺជាមនុស្សតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ  ដែលបានយល់ពីហេតុផលច្បាស់លាស់។ លោកបានជ្រាបពីកស្តុតាងប្រឆាំងលើរូបលោក  ឈូក  បណ្ឌិត  ហើយបានកត់សម្គាល់ពីអ្វីដែលជាការគួរឲ្យអស់សំណើចដែលប្រព័ន្ធតុលាការកម្ពុជា  គឺកំពុងតែបំពេញតួនាទី  ហើយបានសម្រេចចាប់យកឱកាសនេះ  និងព្យាយាមសម្រេចគោលដៅដើម្បីយុត្តិធម៌។  ខ្ញុំសង្ឃឹមថា  អ្វីដែលយើងកំពុងតែឃើញនៅពេលនេះ  គឺជាឯករាជ្យភាពរបស់តុលាការដ៏ពិតប្រាកដ ជាជៀងការដាក់កំហុសបន្ថែមលើរដ្ឋាភិបាល ដែលជាការដកការចោទប្រកាន់ដោយការពុំមានភាពជឿជាក់ និងកំហឹងលើសេចក្ដីសម្រេចរបស់សាលាដំបូងខេត្ត។ ទោះជាយ៉ាងណាក្ដី ខ្ញុំសប្បាយចិត្តដែលមានចលនាជាវិជ្ជមាន និងដែលមានការទទួលខុសត្រូវនៅក្នុងប្រព័ន្ធតុលាការ ដែលចុងក្រោយករណីនេះ កំពុងតែស្ថិតក្នុងទិសដៅដ៏ត្រឹមត្រូវ។ យើងនឹងឃ្លាំមើលលើករណីនេះ និងសវនាការដោយយកចិត្តទុកដាក់បំផុត"។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ូ វីរៈ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ១២ ៤០៤ ០៥១) ឬ អ៊ីម៉ែល៖ ouvirak@cchrcambodia.org ឬ លោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ៧៨ ៨០៩ ៩៦០) ឬអ៊ីម៉ែល៖ robert.finch@cchrcambodia.org។**

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក  ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ  (IFEX)  ដែលជាបណ្ដាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា  www.sithi.org  ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព"។